## Indicating disagreement



### រៀនពូកែ

| | |
|---|---|
| ស៊ីណា៖ | សុជាតាឆ្លាតដល់ហើយ។ រៀនអីក៏ឆាប់ចាប់បានដែរ។ ញ៉ាំអីបានឆ្លាតទៅ សុជាតា? |
| សុជាតា៖ | រៀនពូកែមិនមែនមកពីញ៉ាំអីបានរៀនពូកែឯណា។ មានតែខំប្រឹងរៀន។ |
| ស៊ីណា៖ | ខ្ញុំខំប្រឹងរៀនដែរតាស តែកន្លែងខ្លះខ្ញុំស្ដាប់គ្រូពន្យល់ម៉េចក៏នៅតែអត់យល់ដែរ។<br>មកពីអត់មានហ្សែនឆ្លាតទេដឹង។ |
| សុជាតា៖ | ហ្សែនឆ្លាតអីទេ។ ខ្ញុំក៏មានកន្លែងដែលខ្ញុំអត់យល់ដែរ។<br>ស៊ីណាមានចំណាយពេលរៀនថែមទៀតអត់ពេលទៅផ្ទះ? |
| ស៊ីណា៖ | អត់ផង។ អូ ខ្ញុំតែដល់ផ្ទះ ដឹងតែភ្លឹងហើយ។<br>ប្រហែលមកពីអីចឹងហើយបានរៀនអត់សូវចេះសោះ។ |

### សិក្ខាសាលាមានអ្នកចូលរួមតិច

| | |
|---|---|
| ផានិត៖ | សិក្ខាសាលាង៉ែហ្នឹងអត់សូវមានអ្នកម៉ោសោះ។ ម៉ោពីប្រធានបទហ្នឹង<br>គេអត់សូវចាប់អារម្មណ៍មែនហ្ន៎? |
| សុគន្ធ៖ | ខ្ញុំគិតថាមិនមែនម៉ោពីប្រធានបទអេ៎។ ម៉ោពីយើងដាក់ម៉ោងអត់សូវល្អ គេពិបាកម៉ោ។ |
| ផានិត៖ | ប៉ុន្តែ ខ្ញុំឃើញសិក្ខាសាលាផ្សេងៗ គេដាក់ម៉ោងហ្នឹងដែរតាស។<br>ម៉ោពីម៉ោងយើងជាន់ជាមួយម៉ោងគេ ហើយគេទៅសិក្ខាសាលាផ្សេងអស់ទេដឹង។ |
| សុគន្ធ៖ | វាមិនដែល។ បើយើងគិតមើលទៅ<br>អ្នកដែលពាក់ព័ន្ធនឹងប្រធានបទង៉ែហ្នឹងក៏មិនសូវមានច្រើនដែរទេ ហើយអ្នកដែលអត់សូវពាក់ព័ន្ធ<br>ប្រហែលគេគិតថា “អ៊ឹស អត់សូវពាក់ព័ន្ធផង ខ្ជិលទៅម៉ងទៅ”។ |
| ផានិត៖ | ហ្នឹងហើយ អាហ្នឹងមិនដូចខ្ញុំនិយាយដែរ? ថាប្រធានបទយើងអត់សូវមានអ្នកចាប់អារម្មណ៍។ |

| | |
|---|---|
| ដែរតាស | spoken form of ដែរទេតើ = too, also |
| ... ម៉េច ក៏នៅតែ ... | however much [I do this or that], [I] still [don’t ...] |
| ហ្សែន | gene (also spelled សែន), pronunciation: ហ្ស៊ែន |
| ទេដឹង | clause-final: maybe, perhaps |
| ភ្លឹង | here: to sleep right away (literally: to become “straight”) |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ង៉ៃ | spoken form of ថ្ងៃ = day |
| ម៉ោ | spoken form of មក = to come |
| ហ្ន៎ | final particle to soften a statement or request, similar to ណា |
| អេ៎ | spoken form of the question or negation particle ទេ |
| ដាក់ម៉ោង | to set the time |
| ជាន់ជាមួយ | to overlap with |
| ពាក់ព័ន្ធនឹងប្រធានបទ | to have a connection to the topic |
| ខ្ចិលទៅម៉ង់ទៅ | [I'll] skip it, [I'll] skip it this time |
| អាហ្នឹង | this |

## Cultural notes

ដូចនៅក្នុងវប្បធម៌ផ្សេងៗដែរ នៅខ្មែរ ការនិយាយបដិសេធចំពោះគំនិតរបស់នរណាម្នាក់ចំៗតែម្ដង គឺមិនសូវជាការគួរសមនោះទេ។ ពាក្យថា "ចេះភាសាការទូត" មានន័យថា ដឹងអំពីរបៀបនិយាយបដិសេធ ឬរិះគន់ឬបញ្ចុះបញ្ចូលគេដោយមិនធ្វើឲ្យគេអាក់អន់ស្រពន់ចិត្តឬចាប់កំហុសបាន។

| | |
|---|---|
| ចេះភាសាការទូត | [to know how] to be diplomatic |
| បញ្ចុះបញ្ចូល | to persuade, influence, convince |
| អាក់អន់ស្រពន់ចិត្ត | to feel humiliated/bad |

## Additional dialogue

កូន៖ ម៉ាក់ ង៉ៃហ្នឹងមិនបាច់ធ្វើម្ហូបអេ៎ណា។ ទៅញ៉ាំអីនៅក្រៅម៉ង។ ម៉ាក់ឯងចង់ញ៉ាំអី?
ម៉ាក់៖ មិនបាច់អេ៎អី? នាំតែអស់លុយ។
កូន៖ យូរៗម្ដងតាស។ ទៅហាងង៉ៃមុនទៅ ម៉េចដែរ?
ម៉ាក់៖ អត់ទេស។ ហាងង៉ៃមុនហ្នឹង អត់សូវឆ្ងាញ់ហើយថ្លៃទៀត។
កូន៖ អីចឹង ទៅណាវិញ?
ម៉ាក់៖ ទៅហាងគុយទាវធម្មតាជិតហ្នឹងទៅ។
កូន៖ ហើយ ម៉ាក់ឯងនេះយ៉ាប់ម៉ង។ ទៅកន្លែងណារៀងឡូយតិចទៅ។
ម៉ាក់៖ ស្រេចតែកូនឯងទេអីចឹង។ ថាអត់ចង់ឲ្យអស់លុយច្រើនអញ្ចេក។

| | |
|---|---|
| យូរៗម្ដងតាស | just occasionally, just once in a while |
| អត់ទេស | emphatic variant of អត់ទេ = no, not |
| ឡូយ | cool, fancy, luxurious |
| ស្រេចតែកូនឯងទេអីចឹង | ok, up to you then |
| ថា ... អញ្ចេក | I just thought that ... |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.